## ៤.៦-អនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ស្តីពីការកម្រិតរបបម៉ោងកំណត់ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១០ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែម សម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៦ ស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែម

- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់សាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ ឬអ្នកឯកទេសផ្សេងទៀតដែលបង្រៀននិងបំពេញការងារគរុកោសល្យព្រមទាំងបំពេញការងារដែលពាក់ព័ន្ធនឹងការបង្រៀន នៅក្នុងវិស័យអប់រំនិងអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការនៃការផ្ដល់សេវាបង្រៀននិងរៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈស្របតាមអាទិភាពកំណត់ដោយរាជរដ្ឋាភិបាល និងស្របតាមលទ្ធភាពនៃថវិកា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់៖

- របបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមជូនសាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ ឬអ្នកឯកទេសផ្សេងទៀតដែលបង្រៀននិងបំពេញការងារគរុកោសល្យនៅក្នុងវិស័យអប់រំនិងអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ស្របតាមអាទិភាពកំណត់ដោយរាជរដ្ឋាភិបាលនិងស្របតាមលទ្ធភាពនៃថវិកា
- វិធានការគ្រប់គ្រងការប្រើប្រាស់ម៉ោងបន្ថែមនិងការបើកផ្ដល់ប្រាក់ម៉ោងបន្ថែមដល់សាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ ឬអ្នកឯកទេសដែលត្រូវបានឧទ្ទេសនាមឬជ្រើសរើសឱ្យបំពេញការងារបង្រៀន ការងារគរុកោសល្យ ឬការងារពាក់ព័ន្ធនឹងការបង្រៀន
- របបនៃការទទួលខុសត្រូវនិងគណនេយ្យភាពចំពោះការគ្រប់គ្រងនិងការប្រើប្រាស់ម៉ោងបន្ថែម។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់គ្រឹះស្ថានសិក្សាសាធារណៈទាំងអស់ដែលបច្ចុប្បន្នកំពុងស្ថិតក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួង ស្ថាប័នផ្សេងទៀត អាចត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់របបម៉ោងបន្ថែមនិងប្រាក់ម៉ោងបន្ថែមអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈក្រោមឱវាទក្រសួង ស្ថាប័នសាមីនីមួយៗ ផ្អែកលើការសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល បន្ទាប់ពីមានការឯកភាពពីក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤ .-**

វាក្យសព្ទដែលប្រើនៅក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម៖

- ម៉ោងកំណត់ សំដៅដល់ចំនួនម៉ោងក្នុងមួយសប្ដាហ៍ដែលសាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ ឬអ្នកឯកទេស ផ្សេងទៀតមានភារកិច្ចបង្រៀននិងបំពេញការងារគរុកោសល្យ ព្រមទាំងការងារពាក់ព័ន្ធនឹងការបង្រៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ

- ម៉ោងបន្ថែម សំដៅដល់ចំនួនម៉ោងដែលសាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ ឬអ្នកឯកទេសបានបង្រៀននិងបំពេញការងារគរុកោសល្យ ព្រមទាំងការងារពាក់ព័ន្ធនឹងការបង្រៀនលើសពីចំនួនម៉ោងកំណត់។

## ជំពូកទី២
## របបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែម
## ផ្នែកទី១
## របបម៉ោងកំណត់

**មាត្រា៥ .–**

របបម៉ោងកំណត់ប្រចាំសប្តាហ៍ចំពោះ សាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ ឬអ្នកឯកទេស ដែលមានមុខងារនិងឋានៈត្រូវនឹងកម្រិតសិក្សាដែលបង្រៀនមានកំណត់ក្នុងតារាងដូចខាងក្រោម៖

| គ្រឹះស្ថានសិក្សាឬថ្នាក់បណ្តុះបណ្តាល | ចំនួនម៉ោងបង្រៀនទ្រឹស្តីប្រចាំសប្តាហ៍ | ចំនួនម៉ោងណែនាំអនុវត្តរៀបចំការងារបង្រៀន កំណែប្រចាំសប្តាហ៍ |
|---|---|---|
| **ចំណេះដឹងទូទៅ** | | |
| - មត្តេយ្យនិងបឋមសិក្សា | ២០ ម៉ោង | ២០ ម៉ោង |
| - អនុវិទ្យាល័យ | ១៨ ម៉ោង | ២០ ម៉ោង |
| - វិទ្យាល័យ | ១៦ ម៉ោង | ១៨ ម៉ោង |
| **ផ្នែកមុខជំនាញ** | | |
| - បណ្តុះបណ្តាលវិជ្ជាជីវៈ | ១៦ ម៉ោង | ១៨ ម៉ោង |
| - មធ្យមសិក្សាបច្ចេកទេស | ១៤ ម៉ោង | ១៨ ម៉ោង |
| - ឧត្តមសិក្សា | ១២ ម៉ោង | ១៦ ម៉ោង |
| - ក្រោយឧត្តមសិក្សា | ១០ ម៉ោង | ១៤ ម៉ោង |
| **ថ្នាក់បណ្តុះបណ្តាលរយៈពេលខ្លី** | | |
| - ថ្នាក់កម្រិតពាក់កណ្តាលមធ្យម | ១៦ ម៉ោង | - ១ម៉ោងទ្រឹស្តីស្មើនឹង២ម៉ោងពិភាក្សា សំណួរ ឬអនុវត្តជាក់ស្តែង |
| - ថ្នាក់កម្រិតមធ្យម | ១៤ ម៉ោង | - ចំនួនម៉ោងពិភាក្សាសំណួរ ឬអនុវត្តជាក់ស្តែងច្រើនបំផុតត្រឹម២៤ម៉ោង |
| **ថ្នាក់វិក្រឹតការ** | | |
| - ថ្នាក់កម្រិតពាក់កណ្តាលមធ្យម | ១៦ ម៉ោង | - ១ម៉ោងទ្រឹស្តីស្មើនឹង២ម៉ោងពិភាក្សា សំណួរ ឬអនុវត្តជាក់ស្តែង |
| - ថ្នាក់កម្រិតមធ្យម | ១៤ ម៉ោង | - ចំនួនម៉ោងពិភាក្សា សំណួ ឬអនុវត្តជាក់ស្តែងច្រើនបំផុតត្រឹម២៤ម៉ោង |

**មាត្រា៦ .–**

សាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ ឬអ្នកឯកទេសដែលមានក្របខណ្ឌខ្ពស់ ហើយកំពុងបំពេញការងារបង្រៀននៅគ្រឹះស្ថាន សិក្សាសាធារណៈស្របតាមក្របខណ្ឌរបស់ខ្លួន ប៉ុន្តែត្រូវបានជ្រើសរើសឬចាត់តាំងឱ្យទៅបង្រៀននៅគ្រឹះស្ថានសិក្សា សាធារណៈដែលត្រូវប្រើប្រាស់ក្របខណ្ឌទាបជាងក្របខណ្ឌសាមីជន ត្រូវអនុវត្តរបបម៉ោងកំណត់ទៅតាមក្របខណ្ឌរបស់ខ្លួន។

សាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ ឬអ្នកឯកទេសដែលមានក្របខណ្ឌទាប ហើយត្រូវបានជ្រើសរើស ឬចាត់តាំងឱ្យទៅបង្រៀននៅគ្រឹះស្ថានសិក្សាសាធារណៈដែលត្រូវប្រើប្រាស់ក្របខណ្ឌខ្ពស់ជាងក្របខណ្ឌសាមីជន ត្រូវអនុវត្តរបបម៉ោងកំណត់ទៅតាមកម្រិតគ្រឹះស្ថានសិក្សាដែលសាមីជនបានទៅបង្រៀន។

**មាត្រា៧ ._**

ក្របខណ្ឌបច្ចេកទេស ដែលមានភារកិច្ចជួយរៀបចំនិងធ្វើការនៅតាមមន្ទីរពិសោធន៍ រោងជាងសិក្សាត្រូវបំពេញភារកិច្ចប្រចាំសប្តាហ៍តាមការកំណត់ដូចខាងក្រោម៖

- កម្មករមន្ទីរពិសោធន៍និងរោងជាងសិក្សា៣៦ម៉ោង
- បរិវច្ឆេទការី ត្រូវអនុវត្តនៅមន្ទីរពិសោធន៍និងរោងជាងសិក្សា៣០ម៉ោង។

## ផ្នែកទី២

## ម៉ោងបន្ថែម

**មាត្រា៨ ._**

របបម៉ោងបន្ថែមសំដៅដល់ម៉ោងបង្រៀនលើសពីម៉ោងកំណត់ដែលមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះ និងត្រូវបានកំណត់ដូចខាងក្រោម៖

- មន្ត្រីរាជការជាគ្រូបង្រៀនប្រចាំគ្រឹះស្ថានសិក្សាសាធារណៈណាមួយអាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើនបំផុត៤៨ម៉ោងក្នុងមួយខែ ក្នុងគ្រឹះស្ថានសិក្សាសាធារណៈដែលសាមីជនកំពុងបំពេញការងារឬគ្រឹះស្ថានសិក្សាសាធារណៈផ្សេងទៀត
- មន្ត្រីរាជការមិនមែនជាគ្រូបង្រៀនអាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើនបំផុតចំនួន៣២ម៉ោងក្នុងមួយខែ
- អ្នកឯកទេសដែលមិនមែនជាមន្ត្រីរាជការឬឥស្សរជន អាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើនបំផុតចំនួន៥០ម៉ោងក្នុងមួយខែ។

**មាត្រា៩ ._**

គ្រឹះស្ថានសិក្សាសាធារណៈដែលអាចអនុវត្តរបបម៉ោងបន្ថែមបានលុះត្រាតែស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- គ្រឹះស្ថានបានគ្រោងឥណទានថវិកាសម្រាប់របបម៉ោងបន្ថែម
- គ្រឹះស្ថាននោះពុំមានគ្រូបង្រៀនគ្រប់គ្រាន់ដើម្បីបង្រៀនមុខវិជ្ជាស្របតាមនិយាមកំណត់របស់ក្រសួងស្ថាប័នសាមី
- ការប្រើប្រាស់របបម៉ោងបន្ថែមត្រូវមានការអនុញ្ញាតជាមុនពីក្រសួង ស្ថាប័នសាមី
- ការប្រើប្រាស់របបម៉ោងបន្ថែមក្នុងរង្វង់ឥណទានថវិកាដែលផ្តល់ឱ្យគ្រឹះស្ថានក្នុងឆ្នាំនីមួយៗតែប៉ុណ្ណោះ និង
- ត្រូវអនុវត្តបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា១០ ._**

អ្នកដែលមានសិទ្ធិបង្រៀនម៉ោងបន្ថែម ត្រូវបានកំណត់ដូចខាងក្រោម៖

ក-ក្របខណ្ឌផ្ទៃក្នុងគ្រឹះស្ថានសិក្សា

ក.១- មន្ត្រីរាជការជាគ្រូបង្រៀន

- ត្រូវតែជាមន្ត្រីរាជការជាគ្រូបង្រៀនឬសាស្ត្រាចារ្យប្រចាំគ្រឹះស្ថានសិក្សា
- ត្រូវមានលិខិតបង្គាប់ការជាផ្លូវការរបស់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាអនុញ្ញាតឱ្យបង្រៀនម៉ោងបន្ថែម។

ក.២- មន្ត្រីរាជការមិនមែនជាគ្រូបង្រៀន

- មន្ត្រីរាជការមិនមែនជាគ្រូបង្រៀនដែលត្រូវបានជ្រើសរើសឬចាត់តាំងឱ្យបង្រៀនក្នុងគ្រឹះស្ថានសិក្សា
- ត្រូវមានលិខិតបង្គាប់ការជាផ្លូវការរបស់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាអនុញ្ញាតឱ្យបង្រៀនម៉ោងបន្ថែម។

ខ- ក្របខណ្ឌពីខាងក្រៅគ្រឹះស្ថានសិក្សា

គ្រឹះស្ថានសិក្សាអាចប្រើប្រាស់ក្របខណ្ឌពីខាងក្រៅគ្រឹះស្ថាន ដើម្បីបង្រៀនក្នុងគ្រឹះស្ថានរបស់ខ្លួនបាន ក្នុងករណីដែលគ្រឹះស្ថានមិនអាចរកបានធនធានមនុស្សផ្ទាល់របស់គ្រឹះស្ថានសម្រាប់ការបង្រៀន។

ការប្រើប្រាស់ក្របខណ្ឌពីខាងក្រៅគ្រឹះស្ថានសិក្សា ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

ខ.១- មន្ត្រីរាជការជាគ្រូបង្រៀនឬមន្ត្រីរាជការមិនមែនជាគ្រូបង្រៀន

- ត្រូវមានលិខិតអនុញ្ញាតពីប្រធានអង្គភាពដើមដែលគ្រប់គ្រងផ្ទាល់សាមីជន
- ត្រូវមានលិខិតបង្គាប់ការជាផ្លូវការរបស់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាអនុញ្ញាតឱ្យបង្រៀនម៉ោងបន្ថែម។

ខ.២- អ្នកឯកទេសមិនមែនជាមន្ត្រីរាជការឬឥស្សរជន

- ត្រូវមានលិខិតបង្គាប់ការឬលិខិតអនុញ្ញាតឬលិខិតទទួលស្គាល់ជាផ្លូវការរបស់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា។

**មាត្រា១១ .-**

មន្ត្រីរាជការ ត្រូវបានអនុញ្ញាតឱ្យបង្រៀនម៉ោងបន្ថែមក្នុងករណីដូចខាងក្រោម៖

- មន្ត្រីរាជការជាគ្រូបង្រៀនបានអនុវត្តពេញលេញការបង្រៀនតាមរបបម៉ោងកំណត់ដែលមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះ ដោយការអនុវត្តរបបម៉ោងបន្ថែមនោះជាការបង្រៀនក្នុងគ្រឹះស្ថានសិក្សាតែមួយឬជាការបង្រៀនផ្អែកតាមការចាត់តាំងឱ្យទៅបង្រៀនក្នុងគ្រឹះស្ថានសិក្សាផ្សេងដែលស្ថិតក្នុងភូមិសាស្ត្រឃុំឬសង្កាត់តែមួយ
- មន្ត្រីរាជការជាគ្រូបង្រៀនដែលពុំមានម៉ោងបង្រៀនគ្រប់តាមរបបម៉ោងកំណត់ដូចមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះ និងមិនអាចអនុវត្តការបង្រៀនបានតាមវាក្យខណ្ឌទី១នៃមាត្រានេះ ប៉ុន្តែត្រូវបានជ្រើសរើសឬចាត់តាំងឱ្យទៅបង្រៀនក្នុងគ្រឹះស្ថានសិក្សាដែលស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំ ឬសង្កាត់ផ្សេង ម៉ោងបង្រៀននោះ ត្រូវបានកំណត់ជារបបម៉ោងបន្ថែម
- មន្ត្រីរាជការមិនមែនជាគ្រូបង្រៀនអាចត្រូវជ្រើសរើសឬចាត់តាំងឱ្យបង្រៀនម៉ោងបន្ថែមបានក្នុងករណីដែលសាមីជនបានបំពេញការងារផ្អែករដ្ឋបាលឬការងារជំនាញ យ៉ាងហោច៣២ម៉ោងក្នុងមួយសប្តាហ៍ ឬ១២៨ម៉ោងក្នុងមួយខែ ឬសាមីជនបំពេញការងារផ្អែកលើលទ្ធផលអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា១២ .-**

មន្ត្រីរាជការដែលត្រូវបានជ្រើសរើសឬចាត់តាំងឱ្យបង្រៀនក្នុងវិស្សមកាល គ្រប់ម៉ោងបង្រៀនទាំងអស់ត្រូវគិតជារបបម៉ោងបន្ថែមដែលមានចំនួនច្រើនបំផុតត្រឹម៣០ម៉ោងក្នុងមួយសប្តាហ៍។ ការរៀបចំការបង្រៀនក្នុងវិស្សមកាលនេះ ត្រូវបានអនុញ្ញាតក្នុងលក្ខខណ្ឌដែលការរៀបចំការបង្រៀនមិនអាចធ្វើបានក្នុងពេលធម្មតា និងសម្រាប់ការបណ្តុះបណ្តាលបំប៉នបន្ថែមដល់គ្រូបង្រៀនឬដល់សិស្សជាលក្ខណៈពិសេស។



៦៩

## ផ្នែកទី៣
## ប្រាក់ម៉ោងបន្ថែម

**មាត្រា១៣ .-**

សាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ ឬអ្នកឯកទេស ដែលត្រូវបានជ្រើសរើសឬចាត់តាំងឱ្យបង្រៀនម៉ោងបន្ថែម ដូចមានកំណត់ក្នុងមាត្រា៨ មាត្រា១១ និងមាត្រា១២នៃអនុក្រឹត្យនេះ ត្រូវបានផ្តល់ប្រាក់ម៉ោងបន្ថែមក្នុងមួយម៉ោងដូច មានកំណត់ក្នុងតារាងខាងក្រោម៖

| | គ្រឹះស្ថានសិក្សាឬកម្រិតសិក្សាដែលបង្រៀន | | | |
|---|---|---|---|---|
| សញ្ញាបត្រគ្រូនិងឯកទេសបង្រៀន/ក្របខណ្ឌ | - មធ្យមសិក្សាបច្ចេកទេស<br>- បណ្តុះបណ្តាលវិជ្ជាជីវៈ<br>- មធ្យមសិក្សាទុតិយភូមិ<br>- មធ្យមសិក្សាបឋមភូមិ<br>- បឋមសិក្សា មត្តេយ្យសិក្សា | គ្រឹះស្ថានឧត្តមសិក្សាកម្រិតបរិញ្ញាបត្រ | គ្រឹះស្ថានឧត្តមសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ | គ្រឹះស្ថានឧត្តមសិក្សាកម្រិតបណ្ឌិត |
| បណ្ឌិត | ១៨ ៦០០(មួយម៉ឺនប្រាំបីពាន់ប្រាំមួយរយរៀល) | ២៥ ០០០(ពីរម៉ឺនប្រាំពាន់រៀល) | ៣៥ ០០០(បីម៉ឺនប្រាំពាន់រៀល) | ៤០ ០០០ (បួនម៉ឺនរៀល) |
| បរិញ្ញាបត្រជាន់ខ្ពស់ | ១៨ ០០០(មួយម៉ឺនប្រាំបីពាន់រៀល) | ១៨ ៦០០(មួយម៉ឺនប្រាំបីពាន់ប្រាំមួយរយរៀល) | ២០ ៨០០(ពីរម៉ឺនប្រាំបីរយរៀល) | |
| ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម | ១០ ៤០០(មួយម៉ឺនបួនរយរៀល) | ១៥ ០០០(មួយម៉ឺន ប្រាំពាន់រៀល) | | |
| ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន | ៥ ៥០០(ប្រាំពាន់ប្រាំរយរៀល) | | | |
| ក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម | ៤ ៥០០(បួនពាន់ប្រាំរយរៀល) | | | |

ការកែសម្រួលប្រាក់ម៉ោងបន្ថែមត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងមុខងារសាធារណៈនិង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា១៤ .-**

មន្ត្រីរាជការដែលត្រូវបានជ្រើសរើសឬចាត់តាំងជាផ្លូវការឱ្យទៅបង្រៀននៅសាលាមធ្យមសិក្សាឯកទេស សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានសិក្សាផ្សេងៗរបស់រដ្ឋ ត្រូវអនុវត្តរបបម៉ោងបន្ថែម ដោយគិតប្រាក់ម៉ោងបន្ថែមទៅតាមសញ្ញាបត្រឬក្របខណ្ឌរបស់សាមីជន។

ចំពោះអ្នកឯកទេសផ្សេងៗមិនមែនជាមន្ត្រីរាជការ ដែលត្រូវអញ្ជើញឱ្យមកបង្រៀន ប្រាក់ម៉ោងបន្ថែមត្រូវគិត តាមសញ្ញាបត្រនិងកម្រិតភូមិសិក្សាដែលសាមីជនបានបង្រៀន។

**មាត្រា១៥ .–**

ក្នុងករណីការបង្រៀនមុខវិជ្ជាឬជំនាញណាមួយដែលមានភាពកម្រឬពិសេស តម្រូវឱ្យមានការផ្តល់ប្រាក់កម្រៃបង្រៀនខ្ពស់ជាងកម្រិតប្រាក់ម៉ោងបន្ថែមដែលមានកំណត់ក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ ក្រសួងអប់រំ យុវជន និងកីឡា ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវពិគ្រោះយោបល់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងមុខងារសាធារណៈ ដើម្បីកំណត់ប្រាក់ម៉ោងបន្ថែមដោយឡែកសម្រាប់ការបង្រៀននោះ។

**មាត្រា១៦ .–**

គ្រឹះស្ថានសិក្សាសាធារណៈដែលមានប្រភពចំណូលប្រចាំឆ្នាំផ្ទាល់របស់ខ្លួនពីការបង់ថ្លៃរបស់សិស្ស និស្សិត សកម្មភាពពាណិជ្ជកម្ម ឬអំណោយផ្សេងៗសរុបលើសពី៥០%នៃថវិកាប្រចាំឆ្នាំ មិនត្រូវបានអនុញ្ញាតឱ្យមានការផ្តល់ប្រាក់ម៉ោងបន្ថែមពីថវិកាជាតិឡើយ។

គ្រឹះស្ថានសិក្សាសាធារណៈដែលមានប្រភពចំណូលប្រចាំឆ្នាំពីការបង់ថ្លៃរបស់សិស្ស និស្សិត សកម្មភាពពាណិជ្ជកម្ម ឬអំណោយផ្សេងៗសរុបតិចជាង៥០%នៃថវិកាប្រចាំឆ្នាំឬពុំមានកញ្ចប់ថវិកាផ្ទាល់របស់ខ្លួន ត្រូវបានអនុញ្ញាតឱ្យមានការអនុវត្តរបបម៉ោងបន្ថែមនិងការផ្តល់ប្រាក់ម៉ោងបន្ថែមពីថវិកាជាតិ ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- ថ្នាក់បង្រៀនមានសិស្ស និស្សិតអាហារូបករណ៍របស់រដ្ឋ និង
- សិស្ស និស្សិតអាហារូបករណ៍ក្នុងថ្នាក់នោះ មានចំនួនលើសពី៥០%នៃចំនួន សិស្ស និស្សិតសរុប

គ្រឹះស្ថានសិក្សាសាធារណៈដែលមានលក្ខណៈពិសេស ហើយបច្ចុប្បន្នកំពុងអនុវត្តការផ្តល់ប្រាក់កម្រៃបង្រៀនជូនសាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ អ្នកឯកទេស មន្ត្រីជាប់កិច្ចសន្យា ផ្អែកតាមបទដ្ឋានកំណត់របស់រាជរដ្ឋាភិបាលហើយនោះ ត្រូវអនុវត្តតាមបទដ្ឋានកំណត់ដែលនៅជាធរមាន។

## ជំពូកទី៣
## ការគ្រប់គ្រងនិងការប្រើប្រាស់របបម៉ោងបន្ថែម

**មាត្រា១៧ .–**

ក្រសួង ស្ថាប័ន ដែលមានតម្រូវការប្រើប្រាស់ម៉ោងបន្ថែមនៅតាមគ្រឹះស្ថានសិក្សាសាធារណៈក្រោមឱវាទរបស់ខ្លួន ត្រូវរៀបចំផែនការនៃការប្រើប្រាស់ និងថវិកាសម្រាប់របបម៉ោងបន្ថែមដោយមានការពិគ្រោះយោបល់និងឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ឱ្យបានរួចរាល់ត្រឹមខែឧសភានៃឆ្នាំនីមួយៗ ដើម្បីបញ្ចូលក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនៃឆ្នាំបន្ទាប់។

បន្ទាប់ពីទទួលបានការឯកភាពពីរាជរដ្ឋាភិបាល ចំពោះការអនុញ្ញាតលើការគ្រោងថវិកាសម្រាប់របបម៉ោងបន្ថែម ក្រសួង ស្ថាប័ន ត្រូវធ្វើការបែងចែកនិងជូនដំណឹងអំពីឥណទានថវិកាគ្រោងសម្រាប់របបម៉ោងបន្ថែមដល់គ្រប់គ្រឹះស្ថានសិក្សាក្រោមឱវាទដើម្បីចាប់ផ្តើមអនុវត្ត។

គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវចាត់ចែងការប្រើប្រាស់របបម៉ោងបន្ថែមនិងឥណទានថវិកាសម្រាប់ម៉ោងបន្ថែមត្រឹមកម្រិតនៃភាពចាំបាច់ និងកម្រិតឥណទានថវិកាដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ដោយមិនត្រូវអនុវត្តរបបម៉ោងបន្ថែមលើសពីឥណទានថវិកាកំណត់ឬអនុវត្តដោយគ្មានឥណទានថវិកាបានឡើយ។

ក្នុងពេលអនុវត្តរបបម៉ោងបន្ថែម ប្រសិនបើគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈពិនិត្យឃើញថាឥណទានថវិកាដែលផ្តល់ជូនមិនសមស្របនឹងតម្រូវការ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈត្រូវស្នើសុំមកក្រសួង ស្ថាប័នសាមីតាមឋានានុក្រមដើម្បីពិនិត្យនិងសម្រេចដោយមានការពិគ្រោះយោបល់និងការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងមុខងារសាធារណៈ។

**មាត្រា១៨ .-**

គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈនីមួយៗ ត្រូវរៀបចំឱ្យបានច្បាស់លាស់នូវផែនការបណ្ដុះបណ្ដាលប្រចាំឆ្នាំរបស់គ្រឹះស្ថានសិក្សាសាធារណៈ ដែលរួមមានចំនួនសិស្ស និស្សិត ថ្នាក់រៀន គ្រូបង្រៀន ចំនួនមុខវិជ្ជា ចំនួនម៉ោងបង្រៀន។ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការប្រើប្រាស់របបម៉ោងបន្ថែមក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួនឱ្យបានសមស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា១៩ .-**

ការរៀបចំបើកផ្ដល់ប្រាក់ម៉ោងបន្ថែមសម្រាប់សាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ និងអ្នកឯកទេសផ្សេងទៀតដែលបង្រៀនម៉ោងបន្ថែមនៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ ត្រូវអនុវត្តតាមប្រព័ន្ធគ្រប់គ្រងប្រាក់កម្រៃតាមព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ និងត្រូវបើកផ្ដល់តាមគណនីធនាគាររបស់សាមីជនម្នាក់ៗ។

ការរៀបចំបើកផ្ដល់ប្រាក់ម៉ោងបន្ថែម ត្រូវអនុវត្តតាមបែបបទដូចខាងក្រោម៖

**១- គ្រឹះស្ថានសិក្សាសាធារណៈនៅថ្នាក់ជាតិ**

- បន្ទាប់ពីបានអនុវត្តម៉ោងបង្រៀនបន្ថែមក្នុងខែនីមួយៗ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាក្រោមឱវាទក្រសួងស្ថាប័នថ្នាក់ជាតិ ត្រូវបំពេញឯកសារស្នើសុំការបើកផ្ដល់ប្រាក់ម៉ោងបន្ថែមនិងបញ្ជូនឯកសារទៅនាយកដ្ឋានឬអង្គភាពទទួលបន្ទុកកិច្ចការបុគ្គលិករបស់ក្រសួង ស្ថាប័នសាមី យ៉ាងយូរក្នុងរយៈពេល៧ថ្ងៃបន្ទាប់ នៃថ្ងៃធ្វើការ
- នាយកដ្ឋានឬអង្គភាពទទួលបន្ទុកកិច្ចការបុគ្គលិករបស់ក្រសួង ស្ថាប័នសាមី ត្រូវបញ្ចូលទិន្នន័យផ្អែកតាមឯកសារដែលទទួលបានទៅក្នុងប្រព័ន្ធគ្រប់គ្រងប្រាក់កម្រៃតាមព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈឱ្យបានរួចរាល់យ៉ាងយូរត្រឹមរយៈពេល៧ថ្ងៃបន្ទាប់ ហើយបោះពុម្ពតារាងប្រាក់ម៉ោងបន្ថែមផ្ដល់ទៅឱ្យគ្រឹះស្ថានសិក្សាសាមីដើម្បីរៀបចំអាណត្តិបើកប្រាក់
- ប្រាក់ម៉ោងបន្ថែម ត្រូវបើកផ្ដល់ឱ្យសាមីជនតាមគណនីធនាគារ យ៉ាងយូរត្រឹមសប្ដាហ៍ទី៤នៃខែបន្ទាប់ពីខែដែលផ្ដល់សេវាបង្រៀន។

**២- គ្រឹះស្ថានសិក្សាសាធារណៈនៅថ្នាក់ក្រោមជាតិ**

- បន្ទាប់ពីបានអនុវត្តម៉ោងបង្រៀនបន្ថែមក្នុងខែនីមួយៗ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាថ្នាក់ក្រោមជាតិត្រូវបំពេញឯកសារស្នើសុំការបើកផ្ដល់ប្រាក់ម៉ោងបន្ថែមនិងបញ្ជូនឯកសារទៅមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត យ៉ាងយូរក្នុងរយៈពេល៧ថ្ងៃបន្ទាប់ នៃថ្ងៃធ្វើការ
- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ត្រូវបញ្ចូលទិន្នន័យ ផ្អែកតាមឯកសារដែលទទួលបានទៅក្នុងប្រព័ន្ធគ្រប់គ្រងប្រាក់កម្រៃតាមព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈឱ្យបានរួចរាល់យ៉ាងយូរត្រឹមរយៈពេល៧ថ្ងៃបន្ទាប់ ហើយបោះពុម្ពតារាងប្រាក់ម៉ោងបន្ថែមផ្ដល់ទៅឱ្យមន្ទីរជំនាញពាក់ព័ន្ធដើម្បីរៀបចំអាណត្តិបើកប្រាក់
- ប្រាក់ម៉ោងបន្ថែម ត្រូវបើកផ្ដល់ឱ្យសាមីជនតាមគណនីធនាគារ យ៉ាងយូរត្រឹមសប្ដាហ៍ទី៤នៃខែបន្ទាប់ពីខែដែលផ្ដល់សេវាបង្រៀន។

**មាត្រា២០ .-**

គ្រឹះស្ថានសិក្សាសាធារណៈនីមួយៗត្រូវរក្សាទុកឯកសាររបបម៉ោងបន្ថែមក្នុងរយៈពេលយ៉ាងតិច៥ឆ្នាំ ដើម្បីជាមូលដ្ឋានសម្រាប់ការធ្វើអធិការកិច្ចនិងសវនកម្ម។

ក្នុងឆ្នាំសិក្សានីមួយៗ ក្រសួងមុខងារសាធារណៈនិងមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត អាចចុះធ្វើអធិការកិច្ចនៅតាមគ្រឹះស្ថានសិក្សាសាធារណៈដែលអនុវត្តរបបម៉ោងបន្ថែម ផ្អែកតាមការចាំបាច់ និងមិនតម្រូវឱ្យមានការជូនដំណឹងជាមុនឡើយ។



១០៦

**មាត្រា២១ .-**

ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ អាចរៀបចំសារាចរឬសេចក្ដីណែនាំបន្ថែមដើម្បីធានាការអនុវត្តបទប្បញ្ញត្តិនៃអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៤
## ការទទួលខុសត្រូវចំពោះការប្រើប្រាស់របបម៉ោងបន្ថែម នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ

**មាត្រា២២ .-**

គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការប្រើប្រាស់របបម៉ោងបន្ថែមក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួនឱ្យបានសមស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

ក្នុងករណីគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈនីមួយៗ ត្រូវបានរកឃើញថាបានប្រព្រឹត្តកំហុសពាក់ព័ន្ធនឹង៖

- ការផ្ដល់ព័ត៌មានបំផ្លើសអំពីរបបម៉ោងបន្ថែមនិងប្រាក់ម៉ោងបន្ថែម
- ការផ្ដល់ព័ត៌មានបំផ្លើសអំពីការប្រើប្រាស់សាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ និងអ្នកឯកទេសផ្សេងទៀតដែលបង្រៀនម៉ោងបន្ថែមនៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ
- ការឃុបឃិតគ្នាក្នុងការប្រឌិតរបបម៉ោងបន្ថែម
- ការក្លែងបន្លំឯកសារឬការប្រឌិតព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងរបបម៉ោងបន្ថែមនិងប្រាក់ម៉ោងបន្ថែមផ្ទុយនឹងបទប្បញ្ញត្តិជាធរមាន។

មន្ត្រីរាជការនៃគ្រឹះស្ថានសិក្សាសាធារណៈនោះនឹងត្រូវផ្អាកឱ្យឈប់ពីតំណែងភ្លាមសម្រាប់រយៈពេល៣ខែយ៉ាងតិច ដើម្បីអនុវត្តនីតិវិធីនៃការដាក់ទណ្ឌកម្មខាងវិន័យថ្នាក់ទី២ អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

ការសម្រេចដាក់ទណ្ឌកម្មខាងវិន័យនេះ មិនទាន់រាប់បញ្ចូលការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីនិង/ឬការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់មន្ត្រីរាជការដែលប្រព្រឹត្តកំហុសឡើយ។

**មាត្រា២៣ .-**

មន្ត្រីរាជការដែលមានកាតព្វកិច្ចត្រូវអនុវត្តមុខងារផ្នែកតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ប៉ុន្តែបានខកខានក្នុងការបំពេញមុខងាររបស់ខ្លួនឬធ្វេសប្រហែសមិនបានបំពេញការងារដោយពេញលេញ មន្ត្រីរាជការនោះត្រូវទទួលរងទណ្ឌកម្មខាងវិន័យដោយត្រូវលុបឈ្មោះចេញពីតារាងឡើងថ្នាក់ឬឋានន្តរស័ក្តិប្រចាំឆ្នាំ ឬត្រូវផ្លាស់ការងារដោយបង្ខំតាមវិធានការខាងវិន័យ។ ក្នុងករណីបានប្រព្រឹត្តកំហុសខាងវិន័យធ្ងន់ធ្ងរ មន្ត្រីរាជការនោះត្រូវប្រឈមនឹងទណ្ឌកម្មខាងវិន័យនិងទណ្ឌកម្មផ្សេងទៀតដូចមានចែងក្នុងមាត្រា២២ខាងលើ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា២៤ .-**

ក្នុងឆ្នាំ២០១៧ អត្រាប្រាក់ម៉ោងបន្ថែមថ្មី ដែលមានកំណត់ក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ ត្រូវបានអនុញ្ញាតឲ្យអនុវត្តសម្រាប់តែគ្រឹះស្ថានសិក្សាសាធារណៈក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡាប៉ុណ្ណោះ ក្នុងកម្រិតឥណទានថវិកាមិនលើសពីពីរដងនៃឥណទានថវិកាសរុបសម្រាប់អនុវត្តប្រាក់ម៉ោងបន្ថែមក្នុងឆ្នាំ២០១៦ ដោយ[illegible]



១៨៣

ដែលបានពីការធ្វើវិចារណកម្មថវិកាផ្ទៃក្នុងក្រសួងអប់រំ យុវជន និងកីឡា ដែលត្រូវបានកែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ជាបឋម។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវផ្តល់តារាងប្រើប្រាស់បេឡម៉ោងបន្ថែមនិងប្រាក់ម៉ោងបន្ថែមជូនដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងរៀបចំចាត់ចែងអនុវត្តអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា២៥ .-**

អនុក្រឹត្យនេះត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៧តទៅ។

**មាត្រា២៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ